ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ១៤៤៣ សជណ.ភស

រាជធានីភ្នំពេញ ថ្ងៃទី០៥ខែ ធ្នូ ឆ្នាំ២០១២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សូមជម្រាបជូន**

**ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**កម្មវត្ថុ** : ករណីសំណើពិនិត្យ និងសុំការណែនាំ លើសេចក្តីព្រាងគោលជំហររបស់ប្រទេសកម្ពុជាសម្រាប់សន្និសីទកំពូលលើកទី១៨ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ នៅទីក្រុងដូហា ប្រទេសកាតា។

**យោង** : -លិខិតលេខ១៤០០ សណ ប.ស្ត ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១២ របស់ក្រសួងបរិស្ថាន
-ចំណារសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា រាជរដ្ឋាភិបាលបានឯកភាពលើសេចក្តីព្រាងជំហររបស់ប្រទេសកម្ពុជាសម្រាប់សន្និសីទកំពូលលើកទី១៨ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពី ការប្រែប្រួលអាកាសធាតុ នៅទីក្រុងដូហា ប្រទេសកាតា ដូចខាងក្រោម៖

*ក. ជំហរទូទៅ*

- កម្ពុជាអំពាវនាវដល់ភាគីទាំងអស់ថា រាល់សកម្មភាពឬវិធានការនានាដែលទាក់ទងនឹងការប្រែប្រួលអាកាស-ធាតុ ត្រូវតែអនុលោមទាំងស្រុងទៅតាមគោលការណ៍ និងគោលដៅនានារបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ជាពិសេសគោលការណ៍ យុត្តិធម៌ សមធម៌ ការទទួលខុសត្រូវជាប្រវត្តិសាស្ត្រ ការទទួលខុសត្រូវរួមប៉ុន្តែនៅក្នុងកម្រិតផ្សេងគ្នា និងទៅតាមសមត្ថភាពប្រទេសរៀងៗខ្លួន និងធានាឲ្យបាននូវការអភិវឌ្ឍដោយនិរន្តរភាពនៃបណ្តាប្រទេសកំពុងអភិវឌ្ឍ។

- កម្ពុជាសូមបញ្ជាក់ថាកំណើនសីតុណ្ហភាព នឹងធ្វើឲ្យមានគ្រោះមហន្តរាយដល់ប្រទេសអភិវឌ្ឍតិចតួច ដោយសារតែពួកគេមានភាពងាយរងគ្រោះកម្រិតខ្ពស់ទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ជាពិសេសមានសមត្ថភាពបន្សាំទាប។

- បានទទួលស្គាល់ថាការសម្រេចបាននូវការអភិវឌ្ឍដោយនិរន្តរភាព និងគោលដៅអភិវឌ្ឍសហស្សវត្ស (MDGs) ការកាត់បន្ថយភាពក្រីក្រ ជាអាទិភាពចម្បងរបស់បណ្តាប្រទេសមានការអភិវឌ្ឍតិចតួច។

- អំពាវនាវជាថ្មីថា កថាខណ្ឌទី៩នៃមាត្រាទី៤របស់អនុសញ្ញាUNFCCC បានទទួលស្គាល់ថា ប្រទេសអភិវឌ្ឍតិចតួចគឺជាក្រុមប្រទេសដែលមានតម្រូវការជាក់លាក់ជាច់ដោយឡែក និងមានស្ថានភាពពិសេសទាក់ទងនឹងមូលនិធិ និងការផ្ទេរបច្ចេកវិទ្យា។

*ខ.ការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ និងមធ្យោបាយពាក់ពន្ធ័នានាសម្រាប់ការអនុវត្ត*

- កម្ពុជាសូមគាំទ្រដល់ការផ្តល់អាទិភាពស្មើគ្នាលើការប្តេជ្ញាចិត្ត ក្នុងការអនុវត្តសកម្មភាពបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ សម្រាប់កិច្ចព្រមព្រៀងអាកាសធាតុនាពេលអនាគត។

- កម្ពុជាសូមស្វាគមន៍ចំពោះក្របខ័ណ្ឌការងារបន្ស៊ាំទីក្រុងកាន់គុន និងការគាំទ្រផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស សម្រាប់ការរៀបចំ និងអនុវត្តផែនការបន្ស៊ាំជាតិ (National Adaptation Plans: NAPs) និងកម្មវិធីស្តីពីការបាត់បង់ និងខូចខាត (Loss & Damage) ដែលផ្អែកលើអាទិភាពរបស់ប្រទេស នីមួយៗ។

- សូមគាំទ្រដល់ការបង្កើតគណៈកម្មាធិការបន្ស៊ាំនៅក្រោមសមត្ថកិច្ចនៃសន្និសីទបណ្តាភាគីរបស់អនុសញ្ញា និងអំពាវនាវឲ្យមានការអនុវត្តទៅបានយ៉ាងឆាប់រហ័សនាពេលអនាគត។

- កម្ពុជាសូមអំពាវនាវឲ្យមានការផ្តល់ជូនទាំងស្រុងនូវហិរញ្ញប្បទាន សម្រាប់ចំណាយលើការអនុវត្តសកម្មភាពបន្ស៊ាំ ដោយពុំចាំបាច់តម្រូវឲ្យមានការចំណាយបន្ថែម ឬវិភាគទានឡើយ។

- គាំទ្រដល់ការបង្កើតយន្តការបន្ស៊ាំសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួចនៅក្នុងមូលនិធិអាកាសធាតុបៃតង។

- គាំទ្រដល់ការបង្កើតមជ្ឈមណ្ឌលបន្ស៊ាំអន្តរជាតិ និងមជ្ឈមណ្ឌលបន្ស៊ាំថ្នាក់តំបន់មួយចំនួន ដើម្បីផ្តល់ការគាំទ្រ និងជាធាតុចូលសម្រាប់បង្កើនការយល់ដឹងអំពីបញ្ហានានាដែលទាក់ទងនឹងផលប៉ះពាល់ ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ។

*គ.ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងមធ្យោបាយពាក់ព័ន្ធសម្រាប់ការអនុវត្ត*

- កម្ពុជាសូមស្វាគមន៍ចំពោះការបង្កើតក្រុមការងារបណ្តោះអាសន្នទីក្រុងឌូបាន(ADP)ដែលធ្វើការងារទាក់ទងនឹងលទ្ធផលនៃការចរចាដែលមានលក្ខណៈផ្លូវច្បាប់ ហើយរាល់នីតិវិធីទាំងអស់ត្រូវរៀបចំឲ្យបានរួចរាល់ត្រឹមឆ្នាំ២០១៥ និងដាក់ចូលជាធរមានដើម្បីអនុវត្តចាប់ពីឆ្នាំ២០២០តទៅ។

- កម្ពុជាសូមគាំទ្រឲ្យមានកិច្ចព្រមព្រៀងដំណាក់កាលទី២ នៃពិធីសារក្យូតូ តែត្រូវរិះរកវិធីសាស្ត្រដើម្បីធ្វើឲ្យងាយជាងមុននូវនីតិវិធីអនុវត្តគម្រោងយន្តការអភិវឌ្ឍន៍ស្អាត ដើម្បីឲ្យប្រទេសអភិវឌ្ឍតិចតួចអាចចូលរួមអនុវត្តបានដោយពេញលេញ រួមទាំងគាំទ្រចំពោះការបង្កើតយន្តការទីផ្សារកាបោនថ្មីៗបន្ថែមទៀតដែលស្ថិតនៅក្រោមអនុសញ្ញាUNFCCC។

- គ្រប់ភាគីនៃអនុសញ្ញានៅក្នុងឧបសម្ព័ន្ធទី១ ត្រូវមានកាតព្វកិច្ចតាមផ្លូវច្បាប់ជាមួយការប្តេជ្ញាចិត្ត ឬសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នបន្ថែមទៀត ដោយត្រូវពិចារណាអំពីគោលការណ៍នៃអនុសញ្ញា ដើម្បីកាត់ បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឲ្យបានយ៉ាងតិចបំផុត៤៥ភាគរយត្រឹមឆ្នាំ២០២០ និង៩៥ភាគរយត្រឹមឆ្នាំ២០៥០ នៅក្រោមកម្រិតនៃការបញ្ចេញឆ្នាំ១៩៩០ ដើម្បីធានាបានថាកំហាប់ឧស្ម័នផ្ទះកញ្ចក់ និងអាអេរ៉ូសូល នឹងស្ថិតនៅទាបជាងកម្រិត៣៥០ភាគលាននៃសមមូលឧស្ម័នកាបូនិក ហើយកំណើនសីតុណ្ហភាពមធ្យមស្ថិតនៅក្រោម១,៥អង្សាសេ។

- គាំទ្រការអនុវត្តសកម្មភាពការកាត់បន្ថយការបញ្ចេញឧស្ម័នថ្នាក់ជាតិសមស្រប នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ(NAMAs) តែការកាត់បន្ថយការបញ្ចេញឧស្ម័ននេះត្រូវតែអាចវាស់វែងបាន រាយការណ៍បាន និងផ្ទៀងផ្ទាត់បាន (MRV) តែត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងបង្កើតឡើងដោយយកចិត្តទុកដាក់ផងដែរអំពីស្ថានភាពរបស់ជាតិនីមួយៗ ព្រមទាំងមានការឧបត្ថម្ភ គាំទ្រផ្នែកបច្ចេកវិទ្យា ការកសាងសមត្ថភាព និងហិរញ្ញវត្ថុពីបណ្តាប្រទេសអភិវឌ្ឍ ដើម្បីធានាបាននូវអត្ថប្រយោជន៍ផ្នែកបរិស្ថាន ដោយអនុលោមទៅតាមយន្តការនានា ដែលបានអនុម័តដោយអនុសញ្ញា។

- អំពាវនាវឲ្យបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ធំៗគួរតែបង្ហាញឆន្ទៈ ដើម្បីកាត់បន្ថយដោយស្ម័គ្រចិត្តនូវការបញ្ចេញឧស្ម័នរបស់ខ្លួន ដើម្បីរួមចំណែកសម្រេចឲ្យបាននូវគោលដៅនៃការកាត់បន្ថយការបញ្ចេញឧស្ម័នសកល។

- កម្ពុជាទទួលស្គាល់ថា យន្តការនានាស្តីពីការកាត់បន្ថយបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរិលព្រៃឈើនៅក្នុងប្រទេសកំពុងអភិវឌ្ឍ (REDD+) ត្រូវបានពន្យាពេលក្នុងការអនុវត្ត ទោះបីជាប្រទេសជឿនលឿននិងប្រទេសកំពុងអភិវឌ្ឍបានត្រៀមខ្លួនជាស្រេចដើម្បីជំរុញការអនុវត្តទៅមុខក៏ដោយ។ កម្ពុជាចង់ឃើញភាពជឿនលឿននៃការបង្កើតយន្តការនិងសេចក្តីសម្រេចនានានៅក្នុងកិច្ចពិភាក្សា ជាពិសេសការវិភាគលើផ្នែកហិរញ្ញវត្ថុ និងសកម្មភាពនានាសម្រាប់អនុវត្ត REDD+ នាពេលអនាគត។

### *ឃ. ធនធានហិរញ្ញវត្ថុ*

- កម្ពុជាសូមជំរុញឲ្យបណ្តាប្រទេសអភិវឌ្ឍបង្កើនការប្តេជ្ញាចិត្ត ក្នុងការផ្តល់ហិរញ្ញប្បទានបន្ថែមទៀតដល់ប្រទេសដែលងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ ជាពិសេសបណ្តាប្រទេសមានការអភិវឌ្ឍតិចតួច។

- កម្ពុជាសូមជំរុញឲ្យបណ្តាប្រទេសអភិវឌ្ឍ ផ្តល់ហិរញ្ញប្បទានដល់ប្រទេសកំពុងអភិវឌ្ឍប្រចាំឆ្នាំ ឲ្យបានមួយរយពាន់លានដុល្លារអាមេរិកត្រឹមឆ្នាំ២០២០ ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងទីក្រុងកូផែនហាក (Copenhagen Accord)។

- សូមគាំទ្រដល់ការផ្តល់ហិរញ្ញប្បទានថ្មីៗបន្ថែមទៀត និងដែលអាចព្យាករណ៍បានពីប្រភពសាធារណៈនៃបណ្តាប្រទេសឧបសម្ព័ន្ធទី១ ហើយមូលនិធិសាធារណៈទាំងអស់នោះ គួរតែផ្តល់ឲ្យបានឆាប់រហ័សបំផុតដោយផ្ទាល់ និងងាយស្រួលទទួលយកបាន ដោយអនុលោមទៅតាមមាត្រានានានៃអនុសញ្ញា ជាពិសេស

មាត្រាទី៤។ តាមរយៈយន្តការទីផ្សារ វិស័យឯកជនត្រូវបំពេញបន្ថែម ឬបង្កើនហិរញ្ញវត្ថុសាធារណៈ។ ថវិកាបដិភាគ មិនគួរក្លាយជាឧបសគ្គ ឬលក្ខខណ្ឌសម្រាប់ការទទួលបាននូវមូលនិធិ ឬហិរញ្ញប្បទានទាំងអស់នោះទេ។

- វិភាគទានពីភាគីនៃបណ្តាប្រទេសជឿនលឿននីមួយៗ និងភាគីប្រទេសជឿនលឿនដទៃទៀត ដែលមាននៅក្នុងឧបសម្ព័ន្ធទី២ គួរតែពិចារណាផងដែរអំពីការទទួលខុសត្រូវជាប្រវត្តិសាស្ត្រ និងគោលការណ៍នានានៃអនុសញ្ញាUNFCCC ។

- ការបង្កើននូវការប្តេជ្ញាចិត្តនានាលើសកម្មភាពនៃការប្រែប្រួលអាកាសធាតុ ត្រូវបានយ៉ាងហោចណាស់ ១,៥ភាគរយនៃផលិតផលក្នុងស្រុកសរុប(GDP)ប្រចាំឆ្នាំ របស់បណ្តាភាគីជាប្រទេសជឿនលឿននីមួយៗ ដែលស្ថិតនៅក្នុងឧបសម្ព័ន្ធទី២ និងមិនស្ថិតនៅក្នុងឧបសម្ព័ន្ធទី២ ដែលក្នុងនោះ៦០ភាគរយនៃមូលនិធិនេះ គួរតែប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហាបន្សាំ និង៤០ភាគរយទៀតសម្រាប់សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ លើសពីនេះទៀត ៧០ភាគរយនៃហិរញ្ញវត្ថុសម្រាប់ការបន្សាំ គួរត្រូវតែបែងចែកឲ្យទៅប្រទេសអភិវឌ្ឍតិចតួច ដោយពិចារណាលើមាត្រា៤.៩នៃអនុសញ្ញាUNFCCC។

- កម្ពុជាស្វាគមន៍ចំពោះការបង្កើតមូលនិធិអាកាសធាតុបៃតង និងការបង្កើតគណៈកម្មាធិការអន្តរកាល និងអចិន្ត្រៃយ៍ ព្រមទាំងអំពាវនាវសូមឲ្យមានប្រតិបត្តិការជាបន្ទាន់។

### *ង. ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យា*

- កម្ពុជាគាំទ្រការវាយតម្លៃនៃតម្រូវការបច្ចេកវិទ្យា ជាពិសេសតម្រូវការជាបន្ទាប់សម្រាប់អភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិទ្យាសម្រាប់ការបន្សាំទៅដល់គ្រប់ភាគីនៃប្រទេសកំពុងអភិវឌ្ឍ ជាពិសេសបណ្តាប្រទេសកំពុងអភិវឌ្ឍដែលជាកូនកោះតូចៗ និងប្រទេសមានការអភិវឌ្ឍតិចតួច។ លើសពីនេះទៀត ផែនការសកម្មភាពបច្ចេកវិទ្យាមួយ គួរតែបានរៀបរៀងឡើង និងអនុវត្តដោយមានការគាំទ្រពីបណ្តាប្រទេសជឿនលឿន។ ការផ្ទេរបច្ចេកវិទ្យាគួរតែ ផ្អែកលើតម្រូវការក្នុងប្រទេសនីមួយៗ និងផ្អែកលើគោលការណ៍ រៀនផង ធ្វើការផង។

- កម្ពុជាស្វាគមន៍ចំពោះការបង្កើតយន្តការបច្ចេកវិទ្យាអន្តរជាតិកាន់គុន ដែលប្រតិបត្តិការនៅក្រោមសមត្ថកិច្ចនៃអនុសញ្ញាUNFCCC។

- កម្ពុជាគាំទ្រដល់ការបង្កើតគណៈកម្មាធិការប្រតិបត្តិផ្នែកបច្ចេកវិទ្យា(Technology Executive Committee: TEC) និងមជ្ឈមណ្ឌលបច្ចេកវិទ្យាអាកាសធាតុ និងបណ្តាញការងារ(Climate Technology Centers and Networks: CTCN)។

- គាំទ្រឲ្យមានការផ្តល់នូវការគាំទ្រហិរញ្ញវត្ថុ និងការកសាងសមត្ថភាពជាបន្ទាន់ ដើម្បីរៀបចំកសាងផែនការសកម្មភាពជាតិស្តីពីបច្ចេកវិទ្យា ដែលរួមទាំងមជ្ឈមណ្ឌល CTCN ផងដែរ។

- គាំទ្រដល់វិធានការដាក់លាក់ និងបន្ទាន់ ដើម្បីលុបបំបាត់របាំងដែលកើតចេញពីកម្មសិទ្ធិបញ្ញា នៅក្នុងប្រទេសកំពុងអភិវឌ្ឍ និងប្រទេសមានការអភិវឌ្ឍតិចតួច លើបច្ចេកវិទ្យាដែលមិនបំផ្លាញបរិស្ថាន។

*ឲ. ការកសាងសមត្ថភាព*

- កម្ពុជាសូមគាំទ្រឲ្យមានការបង្កើនសកម្មភាពកសាងសមត្ថភាពដើម្បីកែលម្អការងារ ពង្រឹងសមត្ថភាព និងលទ្ធភាពរបស់ប្រទេសកំពុងអភិវឌ្ឍ។ ការកសាងសមត្ថភាពគួរតែជាដំណើរការជាប់ជាបន្ត ទៅតាមតម្រូវការនៅក្នុងប្រទេសនីមួយៗតាមបែបផែននៃការចូលរួមយ៉ាងពេញលេញ ដើម្បីពង្រឹងសកម្មភាពសម្រាប់ផ្នែកនានា ទៅតាមផែនការសកម្មភាពទីក្រុងបាលី។

- ការកសាងសមត្ថភាពគួរតែគាំទ្រដល់ភាគីជាប្រទេសកំពុងអភិវឌ្ឍ ទៅលើការបង្កើត និងអនុវត្តគម្រោងកសាងសមត្ថភាព និងពង្រឹងសមត្ថភាព នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់តំបន់ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

- គាំទ្រដល់សកម្មភាពដែលផ្តល់អំណាច និងពង្រឹងស្ថាប័នពាក់ព័ន្ធ ដែលរួមទាំងស្ថាប័នបង្គោល និងស្ថាប័នសម្របសម្រួលនានារបស់ជាតិ។

- គាំទ្រនូវភាពចាំបាច់ឲ្យមានការកសាងសមត្ថភាព ដែលអាចវាស់បានតាមរយៈការប្រើប្រាស់សូចនាករសមិទ្ធិផលដែលបានឯកភាពគ្នា និងដែលមានប្រសិទ្ធភាព ហើយភាគីទាំងអស់ត្រូវធ្វើសេចក្តីរាយការណ៍អំពីការរីកចម្រើននានាដែលបានធ្វើឡើង ក្នុងការពង្រឹងសមត្ថភាពលើការប្រែប្រួលអាកាសធាតុ ទៅក្នុងរបាយការណ៍ជាតិរបស់ខ្លួន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ម្យ៉ាស់ លាស់**

**ចម្លងជូន:**

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ក្រសួងធនធានទឹក និងឧតុនិយម

-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន

-ឯកសារ-កាលប្បវត្តិ